# Hepatitis B

*Immunisation Information*

State Government Victoria | Department of Human Services

# រោគថ្លើម Hepatitis B

**Khmer**

## *ព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគ*

## រោគថ្លើម Hepatitis B

រោគថ្លើម Hepatitis B គឺជាវីរុសមួយដែលបណ្តាលឲ្យមានជម្ងឺជាខ្លាំង។ វីរុសនេះត្រូវបានពាំនាំនៅក្នុងឈាម ហើយប៉ះ ពាល់ដល់ថ្លើម ហើយអាចបណ្តាលឲ្យមានជម្ងឺគ្រុនក្តៅ ចង់ក្អួត ធឿយហត់ ទឹកនោមមានពណ៌ដិតខ្លាំង និងស្បែកលឿង។

កុមារទាំងអស់ដែលមានគ្រោះថ្នាក់កើតរោគថ្លើម hepatitis B គួរតែការពារខ្លួនទល់នឹងរោគនេះ។ នៅក្នុងករណីខ្លាំងនោះ រោគថ្លើម Hepatitis B អាចបំផ្លាញថ្លើម ហើយបណ្តាលឲ្យស្លាប់។ អ្នកដទៃទៀតអាចឆ្លងវីរុសនេះ ហើយ"ផ្ទុក"វាក្នុងរយៈពេលយូរ (ថែមទាំងអស់មួយជីវិតទៀតផង) ដោយពុំដឹងខ្លួនឡើយ។ អ្នកទាំងនេះមានគ្រោះថ្នាក់កើតរោគមហារីកថ្លើម និងរោគស្វិតថ្លើមរ៉ាំរ៉ៃហៅថា cirrhosis (មានស្លាកស្នាម) នៅពេលក្រោយមកទៀត។ អ្នកដែល"ផ្ទុក"វីរុស Hepatitis B អាចចម្លងវីរុសនេះទៅកាន់អ្នកដទៃដែលមានសុខភាពល្អ។

នៅក្នុងប្រទេសអូស្ត្រាលី អត្រានៃជម្ងឺថ្លើម Hepatitis B ដែលធ្វើរោគវិនិច្ឆ័យ បានកើនឡើងជាខ្លាំងនៅក្នុងពេល 20 ឆ្នាំកន្លងមកនេះ ដោយមានមនុស្សជាច្រើនពាន់នាក់ កើតរោគនេះរ៉ាំរ៉ៃ។ អត្រានៃការកើតរោគក្នុងចំណោមមនុស្សជំទង់និងមនុស្សទើបនឹងធំ មានច្រើនជាងចំនួនមធ្យមយ៉ាងតិចប្រាំដង។

ជាធម្មតា វីរុស Hepatitis B ឆ្លងរាលដាលតាមរយៈឈាមរបស់អ្នកកើតរោគនេះ ឬពីមាតាទៅកាន់កូន នៅពេលប្រសូតកូន។ នៅពេលមានអាយុកាន់តែច្រើនឡើង វីរុសនេះអាចឆ្លងរាលដាលតាមរយៈសកម្មភាពទាំងពួង ដូចជាការរួមរ័កគ្មានសុវត្ថិភាព ការប្រើគ្រឿងញៀនតាមការចាក់នឹងម្ជុល ការសាក់ឬចាក់ទម្លុះរាងកាយ ការប្រើគ្រឿងសំភារៈដែលមិនសម្លាប់មេរោគ និងកីឡាដែលប៉ះគ្នា នៅពេលដែលមានស្នាមមុត ឬរលាត់។

នៅពេលដែលលោកអ្នកកើតរោគថ្លើម Hepatitis B នេះហើយ គេមិនអាចព្យាបាលវាបានឡើយ ។

## ការចាក់ថ្នាំបង្ការរោគថ្លើម Hepatitis B

កុមារដែលកើតនៅថ្ងៃឬក្រោយថ្ងៃទី 1 ខែឧសភា ឆ្នាំ 2000 នឹងចាប់ផ្តើមគំរោងថ្មី។ កុមារទាំងនេះនឹងចាក់ថ្នាំបង្ការរោគ hepatitis B នៅគ្រាដ៏ខ្លីបន្ទាប់ពីកើត និងនៅក្នុងពេលស្នាក់នៅក្នុងមន្ទីរពេទ្យ។ កំរិតបន្ថែមសំរាប់ការបំពេញសព្វគ្រប់នៃថ្នាំបង្ការរោគ hepatitis B នឹងត្រូវផ្តល់ឲ្យនៅពេលមានអាយុ 2 ខែ 4 ខែ និង 12 ខែ ជាថ្នាំបង្ការរោគ Hib គួបផ្សំគ្នា (Hib/Hepatitis B (COMVAX))។ ថ្នាំបង្ការរោគគួបផ្សំគ្នានេះមានសមាសភាពមួយនៃថ្នាំបង្ការរោគ PedvaxHIB ។

កុមារទាំងអស់ដែលកើតមុនថ្ងៃទី 1 ខែឧសភា ឆ្នាំ 2000 នឹងបំពេញទៅតាមគំរោងចាក់ថ្នាំបង្ការរោគចាស់។ ថ្នាំសព្វគ្រប់នៃ hepatitis B សំរាប់កុមារទាំងនេះ មានរួមទាំងកំរិតដើមដំបូងមួយ
កំរិតទីពីរត្រូវបានផ្តល់ឲ្យនៅ ពេលបួនអាទិត្យក្រោយមកទៀត
ហើយកំរិតទីបីត្រូវបានផ្តល់ឲ្យនៅពេល ប្រាំមួយខែ
ក្រោយពីកំរិតដើមដំបូង។

ឥឡូវនេះ ថ្នាំបង្ការរោគនេះត្រូវបានចាក់ឲ្យកុមារទាំងអស់ដែលរៀននៅ Year 7 នៅឯសាលារៀន។ ឥឡូវនេះ ថ្នាំបង្ការរោគថ្លើម Hepatitis B ចំនួនពីរកំរិត បានត្រូវយល់ព្រមឲ្យប្រើសំរាប់មនុស្សជំទង់ ដែលមានអាយុ 11-15 ឆ្នាំ ហើយជាប់វាក់វិននឹងការឲ្យថ្នាំចំនួនពីរកំរិត ដោយផ្តល់ឲ្យនៅពេល 4-6 ខែ ចន្លោះគ្នា។

ថ្នាំបង្ការរោគនេះដែលប្រើនៅក្នុងប្រទេសអូស្ត្រាលី មានផ្នែកនៃវីរុសដែលកែប្រែពន្ធុហើយ អំបិលអាលុយមីនីញ៉ូមតាមបរិមាណតិចតួច និងជាតិបង្ការកុំឲ្យខូចពុកផុយ។

## *លទ្ធភាពនៃផលលំបាកបន្ទាប់បន្សំរបស់ថ្នាំបង្ការរោគថ្លើម Hepatitis B*

ផលលំបាកបន្ទាប់បន្សំភាគច្រើនមានសភាពតូចតាច ហើយបាត់ទៅវិញយ៉ាងលឿន។ ប្រតិកម្មតទៅនេះ មិនមែនធម្មតាទេ ហើយបើកើតមានក៏វានឹងកើតឡើងនៅពេលដ៏ខ្លីក្រោយពីការចាក់ថ្នាំបង្ការរោគដែរ:

- គ្រុនក្តៅតាមកំរិតទាប។
- ឈឺផ្សារ ក្រហម និងហើម នៅត្រង់កន្លែងចាក់ថ្នាំ។
- ចង់ក្អួត។
- មានអារម្មណ៍មិនស្រួលខ្លួន។
- ឈឺសន្លាក់។

បើប្រតិកម្មមិនសូវធ្ងន់ធ្ងរទាំងនេះពិតជាកើតមានឡើងមែននោះ ផលលំបាកបន្ទាប់បន្សំទាំងឡាយអាចកាត់បន្ថយបាន ដោយ:

- ឲ្យកូនលោកអ្នកផឹកជាតិទឹកថែមទៀត។
- កុំស្លៀកពាក់ខោអាវឲ្យកូនច្រើនហួស។
- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំដែលឈឺ។
- ឲ្យថ្នាំប៉ារ៉ាសេតាម៉ុលទៅឲ្យកូន ដើម្បីបន្ធូរសំរាលគ្រុនក្តៅ (ចូរកត់សំគាល់អំពីកំរិតត្រូវប្រើ សំរាប់អាយុរបស់កូនលោកអ្នក)។

Victoria The Place To Be

បើប្រតិកម្មមានសភាពធ្ងន់ធ្ងរឬមិនបាត់ទៅវិញទេនោះ ឬមួយបើលោកអ្នកមានការបារម្ភអំពីកូនលោកអ្នក  សូមទាក់ទងវេជ្ជបណ្ឌិតលោកអ្នក ឬមន្ទីរពេទ្យ។

## បញ្ជីឆែកមើលមុនពេលចាក់ថ្នាំបង្ការរោគ

មុនពេលចាក់ថ្នាំបង្ការរោគ  សូមប្រាប់វេជ្ជបណ្ឌិតឬគិលានុបដ្ឋាក បើលោកអ្នក ឬ កូនលោកអ្នក :

- □ បានចាក់ថ្នាំបង្ការរោគណាមួយផ្សេងទៀត នៅក្នុងខែកន្លងមកនេះ។
- □ មិនស្រួលខ្លួន នៅនឹងថ្ងៃចាក់ថ្នាំបង្ការរោគ។
- □ មានប្រតិកម្មជាខ្លាំង ទៅនឹងថ្នាំបង្ការរោគណាមួយ។
- □ មានប្រតិកម្មទំនាស់ជាខ្លាំងណាមួយ។
- □ កំពុងប្រើប្រភេទថ្នាំស្តេរ៉ូអ៊ីដណាមួយ (ឧទាហរណ៍: cortisone ឬ prednisone)។
- □ បានប្រើថ្នាំ immunoglobulin ឬការចាក់បញ្ចូលឈាម នៅក្នុងពេលបីខែកន្លងមកនេះ។
- □ មានរោគឬកំពុងទទួលការព្យាបាលរោគ ដែលបណ្តាលឲ្យប្រព័ន្ធការពាររោគមានភាពទន់ខ្សោយ (ឧទាហរណ៍: មហារីកឈាម, មហារីក, HIV/AIDS, ការព្យាបាលប្រើវិទ្យុសកម្ម ឬការព្យាបាលប្រើថ្នាំគីមី)។
- □ រស់នៅជាមួយនរណាមួយដែលមានរោគ ឬកំពុងទទួលការព្យាបាលដែលបណ្តាលឲ្យប្រព័ន្ធការពាររោគមានភាពទន់ខ្សោយ (ឧទាហរណ៍: មហារីកឈាម, មហារីក, HIV/AIDS, ការព្យាបាលប្រើវិទ្យុសកម្ម ឬការព្យាបាលប្រើថ្នាំគីមី)។
- □ មានស្ថានភាពមួយនៃប្រព័ន្ធមជ្ឈមណ្ឌលសរសៃប្រសាទ ដែលកំពុងទទួលការស៊ើបអង្កេតនៅឡើយ។
- □ មានផ្ទៃពោះ។

លោកអ្នកគួរប្រាប់វេជ្ជបណ្ឌិតលោកអ្នក ឬបុគ្គលិកគ្លីនិក អំពីស្ថានភាពទាំងនេះ  ដោយសារតែការចាក់ថ្នាំបង្ការរោគអាចត្រូវបានផ្តល់ឲ្យខុសគ្នា។

### គំរោងពេលចាក់ថ្នាំបង្ការរោគ
*– ដែលគួរធ្វើ-*

| អាយុ | ថ្នាំបង្ការរោគ |
|---|---|
| ពេលកើត | ថ្នាំបង្ការរោគថ្លើម Hepatitis B |
| 2 ខែ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូស / ក្អកមាន់<br>ថ្នាំផឹកបង្ការរោគប្រគ្រីវ<br>ថ្នាំបង្ការរោគ Hib / រោគថ្លើម Hepatitis B |
| 4 ខែ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូស / ក្អកមាន់<br>ថ្នាំផឹកបង្ការរោគប្រគ្រីវ<br>ថ្នាំបង្ការរោគ Hib / រោគថ្លើម Hepatitis B |
| 6 ខែ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូស / ក្អកមាន់<br>ថ្នាំផឹកបង្ការរោគប្រគ្រីវ |
| 12 ខែ | ថ្នាំបង្ការរោគកញ្ជ្រឹល / សាលាទែន / ស្អូច<br>ថ្នាំបង្ការរោគ Hib / រោគថ្លើម Hepatitis B |
| 18 ខែ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូស / ក្អកមាន់ |
| 4 ឆ្នាំ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូស / ក្អកមាន់<br>ថ្នាំផឹកបង្ការរោគប្រគ្រីវ<br>ថ្នាំបង្ការរោគកញ្ជ្រឹល / សាលាទែន / ស្អូច |
| Year 7 នៅសាលារៀន<br>ចន្លោះគ្នាពី 4–6 ខែ | ថ្នាំបង្ការរោគថ្លើម Hepatitis B (កំរិតទី 1)<br>ថ្នាំបង្ការរោគថ្លើម Hepatitis B (កំរិតទី 2) |
| មុនចាកចេញពីសាលា<br>15–19 ឆ្នាំ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូសមនុស្សពេញវ័យ |
| ក្រោយពីប្រសូតកូន សំរាប់ស្ត្រីមិនចាក់ថ្នាំបង្ការរោគ | ថ្នាំបង្ការរោគកញ្ជ្រឹល / សាលាទែន / ស្អូច |
| 50 ឆ្នាំ | ថ្នាំបង្ការរោគខាន់ស្លាក់ / តេតាណូសមនុស្សពេញវ័យ |
| លើសពី 50 ឆ្នាំ<br>(ជនជាតិដើម Aboriginal & Torres Strait Islander) | ថ្នាំបង្ការរោគសួត Pneumococcal (រៀងរាល់ 5ឆ្នាំ)<br>ថ្នាំបង្ការរោគគ្រុនផ្តាសាយ (រាល់ឆ្នាំ) |
| លើសពី 65 ឆ្នាំ | ថ្នាំបង្ការរោគសួត Pneumococcal (រៀងរាល់ 5ឆ្នាំ)<br>ថ្នាំបង្ការរោគគ្រុនផ្តាសាយ (រាល់ឆ្នាំ) |

យើងសូមថ្លែងអំណរគុណ Department of Health and Aged Care (ក្រសួងសុខាភិបាលនិងថែទាំជនចាស់ជរា) ចំពោះការរួមចំណែកក្នុងការផ្តល់ពត៌មាននេះ។

Published by Public Health Group, Victorian Government Department of Human Services.
May 2002 (0650202F)